# សន្និបាតអប់រំ

## ឧត្តមានុវត្តនៃកំណែទម្រង់គ្រឹះស្ថានសិក្សា

# របាយការណ៍សង្ខេបស្ដីពី លទ្ធផល
# ការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០២២-២០២៣

**បង្ហាញដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន**
**រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា**

*ថ្ងៃអាទិត្យ ៧រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤*

# មាតិកា

## ១. សេចក្តីផ្តើម

## ២. លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា

- វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា
- វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល
- វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៩ចំណុច
- វឌ្ឍនភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូ
- វឌ្ឍនភាពនៃការគ្រប់គ្រង និងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ

## ៣. សេចក្តីសន្និដ្ឋាន

# ១. សេចក្តីផ្តើម

– ឆ្នាំសិក្សា ២០២២-២០២៣ ជាឆ្នាំចុងក្រោយ ដែលក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៩-២០២៣ ស្របតាមយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ក្រោមការដឹកនាំដ៏ឆ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៦ នៃរដ្ឋសភា។ ក្រសួង និងអ្នកពាក់ព័ន្ធបានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់ ដូចជា ការបង្កើនការចូលរៀនប្រកបដោយសមធម៌នៅគ្រប់ភូមិសិក្សា ជាពិសេសការអប់រំកម្រិតមូលដ្ឋាន ៩ឆ្នាំ តាមរយៈការបង្កលក្ខណៈសម្បត្តិអនុគ្រោះឱ្យកូនចៅប្រជាជនដែលជួបការលំបាកមានលទ្ធភាពចូលរៀន រៀនបន្ត ការពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សា ការដោះស្រាយការខាតបង់ការសិក្សាក្នុងបរិបទកូវីដ១៩ និងការបង្កើនអាហារូបករណ៍សម្រាប់សិស្សនិងនិស្សិតមកពីគ្រួសារក្រីក្រ។ល។ គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំក៏ត្រូវបានពង្រឹងតាមរយៈការលើកកម្ពស់ វិជ្ជាជីវៈគ្រូបង្រៀន និងការលើកទឹកចិត្ត ព្រមទាំងបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំគ្រប់លំដាប់ថ្នាក់។ល។

# ១. សេចក្តីផ្តើម (ត)

– ក្នុងនីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការអភិវឌ្ឍមូលធនមនុស្សជាអាទិភាពទី១ នៅក្នុងយុទ្ធសាស្រ្តបញ្ចកោណ-ដំណាក់កាលទី១ ដោយផ្តោតលើការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា។ **សម្តេចមហាបវរធិបតី** ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់អនុសាសន៍គន្លឹះ ៤ចំណុចដល់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់អនុវត្ត រួមមាន៖ ទី១.ការពង្រឹងអភិបាលកិច្ចសាលារៀន ទី២.ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស ទី៣.ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យ គុណភាពចំណីអាហារនៅតាមសាលា និងទី៤.ការជំរុញ និងលើក ទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ។

# ២. លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា

# វឌ្ឍនភាពនៃការផ្ដល់សេវាអប់រំ យុវជន និងកីឡា

## ផ្នែកបរិមាណវិស័យ

- ឆ្នាំសិក្សា២០២៣-២០២៤ សាលារៀនចំណេះទូទៅ និងមត្តេយ្យសិក្សាមាន ១៩ ៣៤១ កើន ៥១១ ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣ ក្នុងនោះសាលាមត្តេយ្យសិក្សាគ្រប់រូបភាព ៨ ៨៩១សាលា/កន្លែង (សាធារណៈ ៤ ៦៩៤ សហគមន៍ ៣ ២៩០ និងឯកជន ៩០៧) សាលាបឋមសិក្សា ៨ ២៥២ (ឯកជន ៨៥៤) អនុវិទ្យាល័យ ១ ៣៤១ (ឯកជន ៩៩) និងវិទ្យាល័យ ៨៩៧ (ឯកជន ៣១៦ វិទ្យាល័យធនធាន ៦៧ និងវិទ្យាល័យអប់រំពិសេស ៦)។
- គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** មាន ៤ ៥៤៥ ខ្នង ស្មើ ២៩ ៧០៥ បន្ទប់។
- គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន ១៨៩ (កើន ៥៧) ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៧៩ (កើន ៣១) និងគ្រឹះស្ថានឧត្តមសិក្សាឯកជន ១១០ (កើន ២៦) ដែលមានទីតាំងស្ថិតនៅ ២៥ ខេត្ត និងរាជធានី។

# វឌ្ឍនភាពនៃការផ្ដល់សេវាអប់រំ យុវជន និងកីឡា

- កុមារតូចទទួលបានសេវាអប់រំគ្រប់រូបភាព ៤០០ ៩៥៩នាក់ (កើន ៣,៥៣ភាគរយ) ស្រី ២០១ ២៩០នាក់ (កើន ៣,៧១ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ កុមារអាយុ ៥ឆ្នាំ មាន ២១៨ ៩៥០នាក់ (កើន ២,៣៩ភាគរយ) ស្រី ១០៨ ២៣៤នាក់ (កើន ២,៥៥ភាគរយ)។
- សិស្សបឋមសិក្សាមាន ២ ២៦៥ ៧៨៣នាក់ (កើន ២,៩៨ភាគរយ) ស្រី ១ ០៨៦ ៨៩២នាក់ (កើន ២,៨៦ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ ការចូលរៀននៅបឋមសិក្សាសម្រេចបានអត្រាពិតនៃការសិក្សា ៩៩,៦ភាគរយ កើន ៣,៩ភាគរយ ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។
- សិស្សមធ្យមសិក្សាបឋមភូមិមាន ៧១១ ១១៣នាក់ (កើន ២,៤៤ភាគរយ) ស្រី ៣៧៨ ២៤៧នាក់ (កើន ៤,៤៩ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ ការចូលរៀននៅមធ្យមសិក្សាបឋមភូមិសម្រេចបានអត្រារួមនៃការសិក្សា ៦៥,៥ភាគរយ (កើន ០,៧ភាគរយ) ស្រី ៦៩,៩ភាគរយ (កើន ០,៥ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា ២០២២-២០២៣។

# វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា

- សិស្សមធ្យមសិក្សាទុតិយភូមិមាន ៤៣០ ៧៩២នាក់ (កើន ៧,២៦ភាគរយ) ស្រី ២៣៧ ២៩៨នាក់ (កើន ៨,៥៦ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា ២០២២-២០២៣។ ការចូលរៀននៅមធ្យមសិក្សាទុតិយភូមិសម្រេចបានអត្រារួមនៃការសិក្សា ៤៦,៧ភាគរយ (កើន ២,៥ភាគរយ) ស្រី ៥២,៨ភាគរយ (កើន ៣,៦ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា ២០២២-២០២៣។
- សិស្សមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេសមាន ៣ ៥១២នាក់ (កើន ៧,៧៦ភាគរយ) ស្រី ១ ២៤៦នាក់ (កើន ៧,៤១ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។
- និស្សិតឧត្តមសិក្សា ២៨៤ ៥៩៩នាក់ (កើន ៣៦,១៣ ភាគរយ) ស្រី ១៤៨ ៧៥៧នាក់ (កើន ៥៥,៥៧ ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២១-២០២២។ និស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង ៣៣ ០១៨នាក់ ស្រី ៤២,២៦ភាគរយ ថ្នាក់បរិញ្ញាបត្រ ២៣៧ ២៤៣នាក់ ស្រី ៥៤,៨៦ភាគរយ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ១៣ ០០៨នាក់ ស្រី ៣៤,៧០ ភាគរយ និងថ្នាក់បណ្ឌិត ១ ៣៣០នាក់ ស្រី ១០,៤៥ភាគរយ។ និស្សិតសិក្សាជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា (STEAM) កើនពី ២៥,៦ភាគរយ នៅឆ្នាំសិក្សា២០២១-២០២២ ដល់ ៣១,២១ ភាគរយ នៅឆ្នាំសិក្សា២០២២-២០២៣។

# វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា

- អ្នកសិក្សាបានទទួលការអប់រំគ្រប់កម្មវិធី ៤០ ៨៤៤នាក់ (ថយ ១៨,៧២ភាគរយ) ស្រី ២២ ៣៨២នាក់ (ថយ ១៦,១០ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។
- ក្រុមប្រឹក្សាកុមារកម្ពុជានៅតាមគ្រឹះស្ថានសិក្សា ៨ ៩៨០ មានសមាជិក ១ ៥៦៣ ២៩៤នាក់ (ថយ ០,៨៤ ភាគរយ) ស្រី ៧៨៦ ៩៨៣នាក់ (ថយ ៣,០៣ភាគរយ) និងក្រុមប្រឹក្សាយុវជនកម្ពុជានៅតាមគ្រឹះស្ថានសិក្សា ៦០៦ មានសមាជិក ៣៧៤ ៦៨៤នាក់ (កើន ៣,៩០ភាគរយ) ស្រី ២០៤ ៥៩៤នាក់ (កើន ៤,១៣ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ សមាជិកកាយរឹទ្ធិជាតិកម្ពុជា ១៨០ ០០០នាក់ (កើន ២,៨៥ភាគរយ) ស្រី ៤៩ភាគរយ។
- ក្រសួងបានប្រមូលផ្តុំគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ ១ ៤៣៨នាក់ កើន ៣៨,៨ភាគរយ ធៀបទៅនឹងឆ្នាំ ២០២២ មកធ្វើការហាត់ហ្វឹកហ្វឺនបង្កើនសមត្ថភាពបច្ចេកទេសលើ ៤៣ប្រភេទកីឡា និង ១៣ប្រភេទកីឡាជនមានពិការភាព ដើម្បីត្រៀមប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅឆ្នាំ២០២៣ និងចូលរួមប្រកួតកីឡាជាលក្ខណៈអន្តរជាតិនានា។ ក្រសួងបានបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡាកម្រិត១២+២ ចំនួន ៧៥នាក់ ស្រី ៨នាក់ និងកម្រិតបរិញ្ញបត្រ ១២+៤ ចំនួន ៧១នាក់ ស្រី ១២នាក់។

# វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា

- បុគ្គលិកអប់រំមាន ១២៤ ៥១៧នាក់ (ថយ ០,៨៥ភាគរយ) ស្រី ៥៩ ១៦៥នាក់ ធៀបទៅនឹងឆ្នាំ២០២២ ក្នុងនោះ ថ្នាក់ជាតិ ៤ ៩៧៨នាក់ (ថយ ១,៩៦ភាគរយ) ស្រី ១ ៦៥៨នាក់ និងថ្នាក់ក្រោមជាតិ ១១៩ ៥៣៩នាក់ (ថយ ០,៨១ភាគរយ) ស្រី ៥៧ ៥០៧នាក់។ បុគ្គលិកមិនបង្រៀន ៣៣ ៣៥៥នាក់ ស្រី ១០ ៦៥៣នាក់ និងបុគ្គលិកបង្រៀន ៨៦ ១៨៤នាក់ ស្រី ៤៦ ៨៥៤នាក់។

# វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា

## ផ្នែកគុណវិស័យ

- ក្រសួងបានសម្រេចអាទិភាពកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា និងអនុវត្តនូវកិច្ចការមួយចំនួនដូចជា កំណែទម្រង់សាលារៀន ពង្រឹងអភិបាលកិច្ចសាលារៀន អនុម័តកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាគ្រប់ភូមិសិក្សា កែលម្អការបណ្តុះបណ្តាលគ្រូនិងវិក្រឹតការគ្រូបង្រៀន អភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ និងរៀបចំផែនការសកម្មភាព ដើម្បីអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត កែលម្អវិធីសាស្រ្តបង្រៀន ជំរុញការសិក្សាមុខវិជ្ជាវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា លើកកម្ពស់ការអប់រំឌីជីថល អភិវឌ្ឍជំនាញសតវត្សរ៍ទី២១សម្រាប់យុវជន យកចិត្តទុកដាក់លើសុខភាពរបស់សិស្ស បង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅកម្រិតឧត្តមសិក្សា អភិវឌ្ឍវិស័យអប់រំកាយនិងកីឡា ពង្រឹងសមត្ថភាពស្ថាប័ន និងកសាងប្រព័ន្ធអប់រំជំរុញការចូលរួម និងភាពជាម្ចាស់របស់មាតាបិតា សហគមន៍ និង វិស័យឯកជនក្នុងការអប់រំ។
- ក្រសួងបានជ្រើសរើសសាលាគោលដៅដើម្បីដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូ ៧៩៣ រួមមាន សាលាមត្តេយ្យសិក្សា ៩៦ សាលាបឋមសិក្សា ៣៤៨ និងសាលាមធ្យមសិក្សា ៣៤៩។ សាលារៀនជំនាន់ថ្មី ១១កន្លែង ក្នុងនោះសាលាបឋមសិក្សា៤ និងសាលាមធ្យមសិក្សា៧។

# វឌ្ឍនភាពនៃការផ្ដល់សេវាអប់រំ យុវជន និងកីឡា

- ភាគរយកុមារអាយុ ៦ឆ្នាំ បានឆ្លងកាត់សេវាអប់រំកុមារតូចគ្រប់រូបភាព និងបានចូលរៀនថ្នាក់ទី១ ចំនួន ៧៧,៨១ ភាគរយ (កើន ៧,៩១ភាគរយ) ស្រី ៧៧,៩២ភាគរយ ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣
- អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមាន ៨៩,២ភាគរយ (កើន ២,៤ភាគរយ) ប្រុស ៨៦,៣ភាគរយ (កើន ១,០ភាគរយ) ស្រី ៩២,៣ភាគរយ (កើន ២,៩ភាគរយ) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣
- អត្រាឆ្លងភូមិសិក្សានៅបឋមសិក្សា ៨៦,៦ភាគរយ (កើន ២,៩ភាគរយ) ប្រុស ៨១,៤ភាគរយ (ថេរ) ស្រី ៨៩,០ ភាគរយ (កើន ៣,១ភាគរយ) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣
- ផលធៀបសិស្ស-គ្រូ ៤៥,៥ (កើន ០,៧) ផលធៀបសិស្ស-ថ្នាក់រៀន ៣២,៥ (ថេរ) ផលធៀបសិស្ស-បន្ទប់រៀន ៤៣,៨ (ថេរ) និងផលធៀបថ្នាក់រៀន-បន្ទប់រៀន ១,៣ (ថេរ) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣
- អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៦០,៩៧ភាគរយ (កើន ១,២៧ភាគរយ) ស្រី ៦៦,៣៧ ភាគរយ (កើន ១,៨៧ភាគរយ) និងប្រុស ៥៥,៦៩ភាគរយ (កើន ០,៧៩ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។

# វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា

- អត្រាឆ្លងកម្រិតមធ្យមសិក្សាបឋមភូមិ ៨៦,៦ភាគរយ (កើន ២,៩ភាគរយ) ស្រី ៨៩,០ភាគរយ (កើន ៣,១ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣
- អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិ ៥៣,៥៥ភាគរយ (កើន ៩,២៥ភាគរយ) ស្រី ៥៥,១០ភាគរយ (កើន ១៥,៥ភាគរយ) និងប្រុស ៥១,៧៦ភាគរយ (កើន ២,១៨ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣
- ផលធៀបសិស្ស គ្រូមធ្យមសិក្សាបឋមភូមិ ២៣,០ (ថយ ០,១) និងមធ្យមសិក្សាទុតិយភូមិ ២៤,៦ (កើន ១,០) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣
- ផលធៀបសិស្ស ថ្នាក់រៀនមធ្យមសិក្សាបឋមភូមិ ៤៣,២ (ថយ ២,៤) និងមធ្យមសិក្សាទុតិយភូមិ ៤៦,៥ (កើន ១,៣) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣
- ផលធៀបសិស្ស បន្ទប់រៀនមធ្យមសិក្សាបឋមភូមិ ៤៨,៨ (កើន ០,៤) និងមធ្យមសិក្សាទុតិយភូមិ ៤៩,៥ (កើន ១,៣) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។

# វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា

- ឆ្នាំសិក្សា២០២២-២០២៣ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ១៦៥ ១៣៨នាក់ ស្មើ ៩៤,៥៤ភាគរយ (ថយ ០,២១ភាគរយ) ស្រី ៩១ ២២៧នាក់ ស្មើ ៩៦,៩០ភាគរយ (ថយ ០,១៥ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា ២០២១-២០២២ ដោយមានកំណត់និទ្ទេសល្អ ល្អបង្គួរ និងមធ្យម។
- ឆ្នាំសិក្សា២០២២-២០២៣ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៩៨ ៤៦០នាក់ ស្មើ ៧២,៨៩ ភាគរយ ស្រី ៥៦ ៤៩២នាក់ ស្មើ ៧៨,០៩ភាគរយ ក្នុងនោះបេក្ខជននិទ្ទេស A មាន ១ ៦៧៣នាក់ ស្រី ៩៤៧នាក់ និទ្ទេសB មាន ៦ ៩៦៤នាក់ ស្រី ៤ ១៦៦នាក់ និទ្ទេស C មាន ១៨ ៣០៨នាក់ ស្រី ១១ ៥១៩នាក់ និទ្ទេស D មាន ៣៤ ២៤៦នាក់ ស្រី ២០ ៣២១នាក់ និងនិទ្ទេស E មាន ៣៧ ២៦៩នាក់ ស្រី ១៩ ៥៣៩នាក់។ បេក្ខជននិទ្ទេស A បានទទួលរង្វាន់លើកទឹកចិត្តពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- ឆ្នាំសិក្សា២០២២-២០២៣ បេក្ខជនផ្នែកអប់រំបច្ចេកទេសបានប្រឡងបញ្ចប់ឆ្នាំទី១ ឆ្នាំទី២ និងប្រឡងជាប់សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត៣ ចំនួន ២ ៧៨៩នាក់ ស្មើ ៩៧,២១ភាគរយ ស្រី ១ ០៣៦នាក់ ស្មើ ៩៩,០៤។ សិស្សនិទ្ទេស A ១៨នាក់ ស្រី ១៤នាក់។

# វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា

- និស្សិតបញ្ចប់ការសិក្សា ៤៩ ៦៨៥នាក់ (កើន ៦,៩៧ភាគរយ) ស្រី ២៨ ៥១៨នាក់ (កើន ៤០,១៨ភាគរយ) ក្នុងនោះ ថ្នាក់បរិញ្ញាបត្ររង ៧ ៧៧៥នាក់ ស្រី ៤ ២០១នាក់ ថ្នាក់បរិញ្ញាបត្រ ៣៨ ៥៩៤នាក់ ស្រី ២៣ ២០៦នាក់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៣ ២០២នាក់ ស្រី ១ ០៩៦នាក់ និងថ្នាក់បណ្ឌិត ១១៤នាក់ ស្រី ១៥នាក់។ និស្សិតអាហារូបករណ៍កម្ពុជាបានបញ្ចប់ការសិក្សាពីបរទេស ៦៣០នាក់ ស្រី ១១៣នាក់ ស្មើ ២០,៥៧ភាគរយ។
- អ្នកសិក្សាបានបញ្ចប់កម្មវិធីអប់រំក្រៅប្រព័ន្ធ ៤៤ ៣៧៣នាក់ (កើន ១៤,៣៦ភាគរយ) ស្រី ២៣ ៤៦២នាក់ (កើន ៨,៥៥ភាគរយ) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ អ្នកសិក្សាកម្មវិធីសមមូលបឋមសិក្សាប្រឡងជាប់ ៣ ២៧៩នាក់ ស្រី ១៣២៨នាក់ និងមធ្យមសិក្សាបឋមភូមិអប់រំប្រឡងជាប់ ២០៦នាក់ ស្រី ៣៨នាក់។ អ្នកសិក្សាថ្នាក់បំពេញវិជ្ជាបឋមភូមិប្រឡងជាប់ ៦៩១នាក់ ស្រី ១៧៤នាក់ និងទុតិយភូមិប្រឡងជាប់ ១ ៨៦៤នាក់ ស្រី ៦៤៣នាក់។

# វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា

- ក្រសួងបានរៀបចំចលនាប្រឡងប្រណាំង ៣ល្អ "កូនល្អ សិស្សល្អ មិត្តល្អ" ទទួលបានពានរង្វាន់ធ្វើមប្រចាំឆ្នាំ ២៩០នាក់ (ថយ ៨២,៩ភាគរយ) ស្រី ៥២ភាគរយ ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។
- ក្រសួងបានរៀបចំការប្រកួតកីឡាលក្ខណៈអន្តរជាតិក្នុងប្រទេស ទទួលបានមេដាយ ៤៧៣គ្រឿង (មេដាយមាស ១២០គ្រឿង មេដាយប្រាក់ ១៣៨គ្រឿង និងមេដាយសំរឹទ្ធិ ២១៤គ្រឿង)។ ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិក្រៅប្រទេស ទទួលបានមេដាយ ១២២គ្រឿង (មេដាយមាស ៣៥គ្រឿង ប្រាក់ ៣៦គ្រឿង និងសំរឹទ្ធិ ៥១គ្រឿង) ក្នុងនោះការប្រកួតជើងឯកពិភពលោក បានមេដាយមាស ៨គ្រឿង ប្រាក់ ៦គ្រឿង និងសំរឹទ្ធិ ១៤គ្រឿង, ការប្រកួតជើងឯកអាស៊ី បានមេដាយមាស ៤គ្រឿង ប្រាក់ ៧គ្រឿង និងសំរឹទ្ធិ ១១គ្រឿង និងការប្រកួតកីឡាអាស៊ីអាគ្នេយ៍ បានមេដាយមាស ២៣គ្រឿង ប្រាក់ ២៣គ្រឿង និងសំរឹទ្ធិ ២៦គ្រឿង។

# វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

| សូចនាករស្នូល | | ឯកតា | ជាក់ស្តែង ២០២២-២៣ | ចំណុចដៅ ២០២៣-២៤ | ជាក់ស្តែង ២០២៣-២៤ | ស្ថានភាព |
|---|---|---|---|---|---|---|
| **គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា** | | | | | | |
| ១. | អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ (ម.សិក្សារដ្ឋ សហគមន៍ និង ឯកជន) | % | ៦៤,៨ | ០,៦៤ | ៦៥,៤ | ↑ |
| | ប្រុស | % | ៦៥,៥ | ៩,៦១ | ៦៤,៥ | ↑ |
| | ស្រី | % | ៦៤,៤ | ៣,៦៤ | ៦៦,៨ | ↑ |
| ២. | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | % | ៨៦,៨ | ៤,៨៩ | ៨៩,២ | → |
| | ប្រុស | % | ៨៥,៣ | ៦,៨៤ | ៨៦,៣ | ↑ |
| | ស្រី | % | ៨៩,៤ | ៧,៩២ | ៩២,៣ | → |
| ៣. | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៥៥,៧ | ៥,៥៥ | ៣,៥៨ | ↑ |
| | ប្រុស | % | ៥១,០ | ០,៤៩ | ៤,៥៦ | ↑ |
| | ស្រី | % | ៦០,៤ | ៩,៥៦ | ០,៦០ | ↑ |

# វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

| សូចនាករស្នូល | | ឯកតា | ជាក់ស្តែង ២០២២-២៣ | ចំណុចដៅ ២០២៣-២៤ | ជាក់ស្តែង ២០២៣-២៤ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា | | | | | | |
| ៤ | ភាគរយសិស្សសម្រេចបានកម្រិតសមត្ថភាពក្រោមកម្រិតមូលដ្ឋាន មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា | | | | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៣* | % | | អនុវត្តនៅឆ្នាំ២០២៣-២៤ | | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៣* | % | | អនុវត្តនៅឆ្នាំ២០២៣-២៤ | | |
| | *គណិតវិទ្យាថ្នាក់ទី៣* | % | | អនុវត្តនៅឆ្នាំ២០២៣-២៤ | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៦* | % | | អនុវត្តនៅឆ្នាំ២០២៤-២៥ | | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៦* | % | | អនុវត្តនៅឆ្នាំ២០២៤-២៥ | | |
| | *គណិតវិទ្យាថ្នាក់ទី៦* | % | | អនុវត្តនៅឆ្នាំ២០២៤-២៥ | | |

# វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

| | សូចនាករស្នូល | ឯកតា | ជាក់ស្តែង ២០២២-២៣ | ចំណុចដៅ ២០២៣-២៤ | ជាក់ស្តែង ២០២៣-២៤ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា | | | | | | |
| ៤ | ភាគរយសិស្សសម្រេចបានកម្រិតសមត្ថភាពក្រោមកម្រិតមូលដ្ឋាន មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា | | | | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៨* | % | | ១៥,៩ | ១៧,៣ | ↓ |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៨* | % | | ៦៥,០ | ៧៨,៧ | ↓ |
| | *គណិតវិទ្យាថ្នាក់ទី៨* | % | | ៣០,៣ | ៤៣,២ | ↓ |
| | *រូបវិទ្យាថ្នាក់ទី៨* | % | | ៤៦,១ | ៦៨,៤ | ↓ |
| | *ការអានភាសាខ្មែរថ្នាក់ទី១១* | % | | ១៧,៥ | កំពុងវិភាគ | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី១១* | % | | ៥២,៩ | កំពុងវិភាគ | |
| | *គណិតវិទ្យាថ្នាក់ទី១១* | % | | ៦៦,៣ | កំពុងវិភាគ | |
| | *រូបវិទ្យាថ្នាក់ទី១១* | % | | ៧៣,៦ | កំពុងវិភាគ | |

# វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

| សូចនាករស្នូល | | ឯកតា | ជាក់ស្តែង ២០២២-២៣ | ចំណុចដៅ ២០២៣-២៤ | ជាក់ស្តែង ២០២៣-២៤ | ស្ថានភាព |
|---|---|---|---|---|---|---|
| **គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា** | | | | | | |
| ៥. | ភាគរយគ្រូបង្រៀនបឋមសិក្សាមានគុណវុឌ្ឍិតាមស្តង់ដាជាតិ | % | ៧៧,៨០ | ៣,៧៧ | ៧៨,១១ | ↑ |
| ៦. | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា(១៨-២២ឆ្នាំ)* | % | ១៤,៩ | ១៥,៧ | ១៧,៩ | ↑ |
| | *ប្រុស* | % | ១៥,៥ | ១៨,៣ | ១៦,៧ | → |
| | *ស្រី* | % | ១៣,២ | ១៤០, | ១៩,៣ | ↑ |
| ៧. | អត្រាអក្ខរកម្មជនពេញវ័យ(អាយុ ១៥ឆ្នាំឡើង)** | % | ៨៤,៧ | ១,៩២ | ៨៤,៧ | → |
| **គោលនយោបាយទី ២ ៖** ពង្រឹងសមត្ថភាពស្ថាប័នដើម្បីក្រថាបដាំល់បគរ៉ែបអ្ដីនម្រ៉សបរងគ់ប្រគង្រ៊ិនំ នាកឹដក្នអជាពភានទ៊ីទិស្តិក័សពភានាជ | | | | | | |
| ៨. | នាយកសាលាបឋមសិក្សា និងមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន | ចំនួន | ២ ៥២០ | N/A | ១ ៤៧៤ | → |

# វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៩ចំណុច

**១) ការបើកសាលារៀនឡើងវិញប្រកបដោយសុវត្ថិភាព ការស្តារឡើងវិញនូវការរៀនសូត្រ និងការបន្តការសិក្សារបស់សិស្ស**

- ការបង្កើតគណៈកម្មការសុខភាពសិក្សានៅតាមសាលារៀន ៩ ៤៦៧សាលា
- ការផ្សព្វផ្សាយគោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹក ស្អាតនិងអនាម័យ
- ការផ្សព្វផ្សាយគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅគ្រឹះស្ថានសិក្សា
- ការផ្សព្វផ្សាយគោលការណ៍បរិស្ថានសាលារៀនបៃតង សាលាស្អាតគ្មានសំរាម នៅគ្រឹះស្ថានសិក្សា
- សាលាមត្តេយ្យសិក្សាសាធារណៈដាច់ដោយឡែក ៩៩,៧ភាគរយ មានបង្គន់អនាម័យ ៨២,៩ភាគរយ មានកន្លែងលាងសម្អាតដៃ ៧៨,៧ភាគរយ មានទឹកស្អាតសម្រាប់ទទួលទានគ្រប់គ្រាន់ និង ៣៨,៤ភាគរយ មានប្រអប់សង្គ្រោះបឋម
- សាលាបឋមសិក្សា ១០០ភាគរយ មានបង្គន់អនាម័យ ៨៦ភាគរយ មានកន្លែងលាងសម្អាតដៃ និង ៨៣ភាគរយ មានទឹកស្អាតសម្រាប់ទទួលទាន
- អនុវិទ្យាល័យ ៩៩,៩០ភាគរយ មានបង្គន់អនាម័យ ៧៩,៥០ភាគរយ មានទឹកស្អាត ៨៤,១០ភាគរយ មានកន្លែងលាងសម្អាតដៃ និង ៤៥,៣០ភាគរយ មានប្រអប់សង្គ្រោះបឋម
- វិទ្យាល័យ ១០០ភាគរយ មានបង្គន់អនាម័យ ៨៦,៧ភាគរយ មានទឹកស្អាត ៨៧,៦ភាគរយ មានកន្លែងលាងដៃ និង ៧២,៥ភាគរយ មានប្រអប់សង្គ្រោះបឋម។

# វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៩ចំណុច

## ២) កំណែទម្រង់សាលារៀន

- ការបង្កើតគំរូកំណែទម្រង់សាលារៀន ៣ប្រភេទគឺ៖សាលារៀនជំនាន់ថ្មី សាលារៀនគំរូ សាលារៀនធម្មតា
- ការដាក់ឱ្យអនុវត្តស្តង់ដាសាលាគំរូ គ្រប់ភូមិសិក្សា
- ការពង្រឹងការគ្រប់គ្រងតាមសាលារៀនផ្តោះទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងផ្លាស់ប្តូរវប្បធម៌សាលារៀន
- ការធ្វើបច្ចុប្បន្នកម្មបញ្ញាត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ ឱ្យស្របតាមកំណែទម្រង់អប់រំ បរិវត្តកម្មអប់រំ ការអប់រំឌីជីថល
- ការបំប៉នសមត្ថភាពស្តីពីការគ្រប់គ្រងតាមសាលារៀន SBM ដល់នាយកសាលា និងគ្រូបង្រៀន ២ ០០០នាក់
- ការវាយតម្លៃជ្រើសរើសគ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣
- ការណែនាំវិធីសាស្ត្របង្រៀនកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងថ្នាក់ទី១ និងវិធីសាស្ត្របង្រៀននិងការប្រើប្រាស់កញ្ចប់សម្ភារៈគណិតវិទ្យា សម្រាប់បំប៉នដល់គ្រូឧទ្ទេសថ្នាក់ជាតិដើម្បីបំប៉នបន្ត ដល់គ្រូបង្រៀនថ្នាក់ទី១
- ការវាយតម្លៃជ្រើសរើសគ្រូល្អ សាលារៀនល្អ នាយកល្អ នឹងអនុវត្តរៀងរាល់ចុងឆ្នាំសិក្សានីមួយៗ។

# វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៥ចំណុច

### ៣) ការអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាពខ្ពស់ តាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- ការអនុម័តក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀន តាមប្រព័ន្ធក្រេឌីត ដោយផ្អែកលើក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនថ្នាក់តំបន់ និងសកល ព្រមទាំងឧត្តមានុវត្តន៍នានា
- ការអនុម័តក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ តាមប្រព័ន្ធអនុវត្តក្រេឌីតបរិញ្ញាបត្រ+១
- ការអនុម័តឯកសារផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៣-២០៣០
- ការអភិវឌ្ឍឯកសារសម្រាប់គាំទ្រការអប់រំគ្រូបង្រៀនបឋមសិក្សា និងអនុវិទ្យាល័យតាមប្រព័ន្ធ១២+៤ បាន ៦៩ ចំណងជើង
- ការពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូនៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
- ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស និងគណៈគ្រប់គ្រងលើ ១១ប្រធានបទ
- ការទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាល (Provider) ៣គ្រឹះស្ថាន
- គ្រូបង្រៀននិងនាយកសាលា ៦ ៦៥៩នាក់ ទទួលបានក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងត្រៀមវាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន។

# វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៩ចំណុច

## ៤) ការអប់រំឌីជីថល

- ការរៀបចំយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន
- ការបង្កើតបន្ទប់ស្ទូឌីយោសម្រាប់ផលិតមាតិកាឌីជីថល ២, ការផលិតវីដេអូជំនួយដល់ការបង្រៀន និងរៀននៅគ្រប់កម្រិតសិក្សាសម្រាប់ផ្សព្វផ្សាយក្នុងប្រព័ន្ធសិក្សាអេឡិចត្រូនិករបស់ក្រសួង
- ការអភិវឌ្ឍសៀវភៅសិក្សាសិក្សាគោលមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) សម្រាប់មធ្យមសិក្សាពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២
- ការអភិវឌ្ឍថ្នាលអប់រំឌីជីថល (e-learning) និងធនធានសិក្សាកម្ពុជា (OER) សម្រាប់ជំនួយគ្រូក្នុងការបង្រៀនតាមអេឡិចត្រូនិកនៅតាមសាលារៀន
- ការបង្កើតក្លឹបសិក្សាសរសេរកូដ សម្រាប់សិស្សានុសិស្សសិក្សានៅតាមសាលារៀន
- ការអនុវត្តកម្មវិធី Arduino និង Robotics រួមជាមួយការសរសេរកូដនៅសាលារៀនជំនាន់ថ្មី
- ការលើកកម្ពស់ការអប់រំឌីជីថល តាមរយៈ ១).ការបញ្ជ្រាបអក្ខរកម្មឌីជីថលទៅក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សា ២).ការអនុវត្តមុខវិជ្ជាឌីជីថល ដូចជាការសរសេរកូដ ការផលិតមនុស្សយន្ត។ល។

# វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៩ចំណុច

**៥) ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា**

- ការរៀបចំបន្ទប់ពិសោធន៍វិទ្យាសាស្ត្រតាមមុខវិជ្ជា បន្ទប់កុំព្យូទ័រនិងបំពាក់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់គ្រូបង្រៀន និងបណ្ណាល័យសតវត្សរ៍ទី២១ និងបំពាក់សម្ភារឧបទេស សម្ភារពិសោធន៍នៅតាមវិទ្យាល័យធនធាន និងសាលារៀនជំនាន់ថ្មី
- ការអនុម័តឯកសារណែនាំការអនុវត្ត STEM ៥មុខវិជ្ជា រួមមាន៖ គណិតវិទ្យា ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដី និងបរិស្ថានវិទ្យា
- ការអនុម័តដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវនៅគ្រឹះស្ថានឧត្តមសិក្សាគោលដៅ ៦
- ការអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា ជាមួយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៦ ដើម្បីគាំទ្រការរៀន និងបង្រៀនតាមបែបឌីជីថល។

# វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៩ចំណុច

## ៦) ការអភិវឌ្ឍជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន

- ការអនុវត្តកម្មវិធីយុវជន២១ ក្រោមប្រធានបទ សហគ្រិនឌីជីថល នវានុវត្តន៍អាជីវកម្ម និងកម្មវិធីអប់រំសហគ្រិនភាព
- ការអប់រំស្តីពីសហគ្រិនភាពឌីជីថលក្នុងកម្មវិធីយុវជន២១ ក្រោមប្រធានបទ «នវានុវត្តន៍អាជីវកម្ម» ដល់យុវជន ៦៥៩នាក់ ស្រី ២៧៤នាក់
- ការបណ្តុះបណ្តាលការរៀបចំផែនការអាជីវកម្ម និងការប្រកួតប្រជែងផែនការអាជីវកម្មស្តីពី ផែនការអាជីវកម្មខ្ញុំ ដល់យុវជន ២១០នាក់ ស្រី ១២៩នាក់
- ការបណ្តុះបណ្តាលជំនាញទន់លើប្រធានបទ ការស្គាល់ខ្លួនឯង ការកំណត់ទស្សនវិស័យ ការងារជាក្រុម និងការដោះស្រាយបញ្ហាដល់យុវជន ១៨០នាក់ ស្រី ១០៤នាក់
- ការបោះជំរំកាយរឹទ្ធិប្អូនថ្នាក់ជាតិលើកទី១ ក្រោមប្រធានបទ "កុមារសតវត្សរ៍ទី២១"
- កម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ និងជំនាញនិយាយសាធារណៈ យុវជនចូលរួម ៣៩៦នាក់ ស្រី ២២៧នាក់ និងការប្រកួតប្រជែងស្នាដៃយុវជនសតវត្សរ៍ទី២១ (គម្រោងSTEM) យុវជនចូលរួម ៥៧០នាក់ ស្រី ២៨០ នាក់

# វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៩ចំណុច

## ៧) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅកម្រិតឧត្តមសិក្សា

- ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា ៤
- ការអនុវត្តកម្មវិធីបណ្ដាញសាកលវិទ្យាល័យសាយប័រកម្ពុជា ដោយគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៦ ដើម្បីគាំទ្រការរៀន និងបង្រៀនតាមបែបឌីជីថល
- ការរៀបចំ និងកែលម្អកម្មវិធីសិក្សា ៧៩ នៅតាមគ្រឹះស្ថានឧត្តមសិក្សា ១១
- ការបណ្ដុះបណ្ដាលបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតសម្រាប់បុគ្គលិកអប់រំ ១៩៩នាក់ នៅតាមគ្រឹះស្ថានឧត្តមសិក្សា១១
- ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងស្ថិតិនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ
- ការតែងតាំងឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំលើកដំបូង ៣២៨នាក់ ក្នុងនោះសាស្ត្រាចារ្យ ៣២រូប សាស្ត្រាចារ្យរង ៥៨នាក់ និងសាស្ត្រាចារ្យជំនួយ ២៣៨នាក់
- ការអនុវត្តគម្រោងស្រាវជ្រាវ ១៩០ (ក្រោមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ១៣ និងគ្រឹះស្ថានឯកជន៥០)។

# វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៩ចំណុច

## ៨) ការពង្រឹងសមត្ថភាពស្ថាប័ន និងការកសាងប្រព័ន្ធអប់រំ

- ការសម្រួចសកម្មភាពអាទិភាពដោយបន្សុំជាមួយនឹងផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងអាទិភាពកំណែទម្រង់
- ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងថវិកាឆ្នាំ២០២៤ ដោយផ្សារភ្ជាប់ជាមួយនឹងផែនការសមិទ្ធកម្ម
- ការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៣ និង ២០២៤ រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០២៤-២០២៨
- ការអនុម័តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម
- ការរៀបចំម៉ូឌុលស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពដាក់ក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS) ការរៀបចំក្របខណ្ឌ និងផែនការសកម្មភាពប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ការពិនិត្យឡើងវិញមុខងារ រចនាសម្ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា។

# វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ ៩ចំណុច

## ៩) ការអភិវឌ្ឍការអប់រំកាយ និងកីឡា

- ការប្រមូលផ្តុំត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីហ្គេម និងត្រៀមលក្ខណៈការប្រកួតកីឡាអន្តរជាតិនានា
- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា
- ការបើកផ្តល់សម្ភារៈកីឡាជូនកីឡាករ កីឡាការិនីសម្រាប់ហាត់ហ្វឹកហ្វឺនគ្រប់គ្រាន់
- ការជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ ទីលានកីឡាបាល់ទាត់សាលាតម្រង់ទិស ៨ទីលាន ក្នុងនោះមានខេត្តត្បូងឃ្មុំ ស្វាយរៀង កំពង់ឆ្នាំង ព្រៃវែង កំពង់ស្ពឺ តាកែវ កណ្តាល និងរាជធានីភ្នំពេញ
- ការរៀបចំកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រសិល្បៈមនុស្សសាស្ត្រឯកទេសអប់រំកាយ
- ការអភិវឌ្ឍសៀវភៅសិក្សាគោលមុខវិជ្ជាគរុកោសល្យ និងវិធីសាស្ត្របង្រៀនអប់រំកាយ និងចងក្រងសៀវភៅទិវាអប់រំកាយនៅមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ៨ និងថ្នាក់ទី៩
- ការបណ្តុះបណ្តាលគ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម និងមន្ត្រីរៀបចំការប្រកួតកើនពី ១ ០៣៦នាក់ ស្រី ២៨៣នាក់ នៅឆ្នាំ២០២២ ដល់ ១ ៤៣៨នាក់ នៅឆ្នាំ២០២៣
- ការប្រមូលផ្តុំក្រុមកីឡាជម្រើសជាតិ និងក្រុមកីឡាជនមានពិការភាពនៅក្នុងប្រទេស និងក្រៅប្រទេស ១ ៣៨៤នាក់ ស្រី ៤៥៥នាក់។

# វឌ្ឍនភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូ

- រាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភា ក្រសួងបានកំណត់នូវកំណែទម្រង់សាលារៀនជាអាទិភាព ដោយផ្តោតលើពង្រឹងការគ្រប់គ្រងដឹកនាំសាលារៀនឆ្ពោះទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ការផ្លាស់ប្តូរវប្បធម៌សាលារៀន និងការពង្រឹងវិន័យ សីលធម៌ ចរិយាធម៌ សុជីវធម៌ គុណធម៌ និងឥរិយាបថល្អរបស់បុគ្គលិកអប់រំនិងសិស្សានុសិស្ស។
- ក្រសួងបានចេញប្រកាសដាក់ឱ្យអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ, សាលាបឋមសិក្សាគំរូ និងសាលាមធ្យមសិក្សាគំរូ ដែលមាន ៥ ស្តង់ដា គឺស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស, ស្តង់ដាទី២៖ ការបង្រៀននិងរៀន, ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍, ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន, និងស្តង់ដាទី៥ ៖ គណនេយ្យភាពរបស់សាលារៀន។ សាលាមត្តេយ្យសិក្សាគំរូ មានស្តង់ដា៥ សូចនាករគន្លឹះ ២៧ និងសូចនាកររង៥៦, សាលាបឋមសិក្សាគំរូ មានស្តង់ដា៥ សូចនាករគន្លឹះ ២៧ និងសូចនាកររង៧១, សាលាមធ្យមសិក្សា មានស្តង់ដា៥ សូចនាករគន្លឹះ ២៧ និងសូចនាកររង ៨២/៨៣។

# វឌ្ឍនភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូ

- ក្រសួងបានជ្រើសរើសសាលារៀនគោលដៅតាមយន្តការរួមពីលើចុះក្រោម (ថ្នាក់នាយកដ្ឋានជំនាញ) និងពីក្រោមឡើង (ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា) ដើម្បីគាំទ្រការអនុវត្តស្តង់ដាសាលារៀនគំរូ។ ការជ្រើសរើសសាលារៀនគោលដៅ គឺផ្អែកតាមលក្ខណៈសម្បត្តិដូចជា ៖ សាលារៀនកំពុងស្ថិតក្នុងគោលដៅនៃគម្រោង/មូលនិធិ/អង្គការដៃគូអភិវឌ្ឍ, សាលារៀនដែលទទួលបានមូលនិធិអភិវឌ្ឍន៍, សាលារៀនដែលមានសិស្សនិទ្ទេស A, សាលារៀនដែលមានសិស្សប្រឡងជាប់លើសលទ្ធផលថ្នាក់ជាតិ, សាលារៀនដែលស្ថិតក្នុងសំណាកនៃតេស្តថ្នាក់ជាតិ និងអន្តរជាតិ។ ក្រសួងបានជ្រើសរើសសាលារៀនគោលដៅដើម្បីដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូ ៧៩៣ រួមមានសាលាមត្តេយ្យសិក្សា ៩៦ សាលាបឋមសិក្សា ៣៤៨ និងសាលាមធ្យមសិក្សា ៣៤៩។
- ក្រសួងបានរៀបចំយន្តការអនុវត្តស្តង់ដាសាលារៀនគំរូ ដូចជា៖ រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តស្តង់ដាសាលារៀនគំរូ, ប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូ, បង្កើតគណៈកម្មការដឹកនាំ និងគណៈកម្មការបច្ចេកទេសអនុវត្តស្តង់ដាសាលារៀនគំរូទាំងបីកម្រិត, ក្រុមការងារចុះជួយគាំទ្រតាមតំបន់ទាំង៥ ដោយមានសមាសភាពចម្រុះថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត។

# វឌ្ឍនភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូ

- ក្រសួងបានរៀបចំផែនការសកម្មភាពច្បាស់លាស់ ចុះជួយគាំទ្រសាលារៀនដើម្បីប្រែក្លាយជាសាលារៀនគំរូ ដោយប្រើប្រាស់កម្លាំងសរុប និងធនធានសរុប ដោយឱ្យអង្គភាពពាក់ព័ន្ធសម្រួចអាទិភាពនិងដាក់ចេញនូវសកម្មភាពលើការសម្រេចស្តង់ដាសាលារៀនគំរូ រួមទាំងការគាំទ្រពីគម្រោងនានា។
- ក្រសួងបានប្រជុំណែនាំ ត្រួតពិនិត្យ និងជំរុញការអនុវត្តដល់គណៈកម្មការ អនុគណៈកម្មការ ក្រុមការងារតាមអនុវិស័យទាំងបី ក្នុងក្របខណ្ឌរួម និងគម្រោង ដើម្បីពិនិត្យវឌ្ឍនភាព បញ្ហាប្រឈម វិធីសាស្ត្រអនុវត្តការងារនិងគាំទ្រសាលារៀនឱ្យបានទាន់ពេលវេលា និងប្រសិទ្ធភាពការងារ ជាពិសេសការរៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល។ ក្រសួងបាននិងកំពុងពង្រឹងប្រព័ន្ធការងារជាបណ្តើរៗ (សមត្ថភាពស្ថាប័ន និងសមត្ថភាពមន្ត្រី) ដោយផ្តោតលើសមិទ្ធកម្មការងារ ដើម្បីធានាការសម្រេចបានស្តង់ដាសាលារៀនកាន់ច្រើនឡើងៗ ពីមួយឆ្នាំទៅមួយឆ្នាំ។
- ក្រសួងបាននិងកំពុងធ្វើការវាយតម្លៃសាលារៀនគោលដៅ ដើម្បីទទួលបានសាលារៀនជាប់ស្តង់ដាចំនួន ១១៥ ក្នុងពេលសន្និបាតអប់រំ ខែមេសា ២០២៤។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

**១. កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិទី២ (USESDP2)**

- ថវិកាសរុប ៖ ៥៣,៥ លានដុល្លារអាមេរិក រយៈពេលអនុវត្តពីឆ្នាំ ២០១៩ ដល់២០២៤
- គម្រោងនេះផ្តោតលើ ១) ការលើកកម្ពស់គុណភាពគ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ២) ការលើកកម្ពស់គុណភាពនិងការឆ្លើយតបទីផ្សារការងារនៃការអប់រំមធ្យមសិក្សាទុតិយភូមិ និង ៣) ការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ការធ្វើផែនការ ការគ្រប់គ្រង និងការផ្តល់សេវាអប់រំ។

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

- ការអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ៖ បានរៀបចំរចនាសម្ព័ន្ធ ផែនការសកម្មភាព កែលម្អកម្មវិធីនានា បំពាក់សង្ហារិមបន្ទប់ពិសោធន៍ កុំព្យូទ័រ និងបញ្ជូនសាស្ត្រាចារ្យទៅសិក្សានៅបរទេស និងកំពុងសាងសង់បណ្ណាល័យថ្មីសម្តេចព្រះសង្ឃរាជ ជួន ណាត និងជួសជុលអាគារបេតិកភណ្ឌ
- ការបំប៉នសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) ១ ១០០នាក់មកពីវិទ្យាល័យធនធាន វិទ្យាល័យបណ្តាញ និងវិទ្យាស្ថានជាតិអប់រំ។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

**១. កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិទី២ (USESDP2)**

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

- ការធ្វើឱ្យប្រសើរឡើងសម្ភារូបវន្តនៅតាមវិទ្យាល័យគោលដៅ
- ការធ្វើឱ្យប្រសើរឡើងការសិក្សាបំណិនជីវិត និងជំនាញ៖ ក).បង្កើតកម្មវិធីមគ្គុទ្ទេសក៍អាជីព (ឆ្លើយតបនឹងយេនឌ័រ) នៅវិទ្យាល័យធនធាន៥០ មានអ្នកចូលរួម ១៥៩ ៩៩៣នាក់, ខ).ផ្ដល់កម្មវិធីសិក្សាបន្ថែមបំណិនស្នែមសម្រាប់សិស្សនៅវិទ្យាល័យធនធាន២០, គ).បង្កើតភាពជាដៃគូ "វិទ្យាល័យ-ឧស្សាហកម្ម នៅវិទ្យាល័យធនធាន៥០ មានអ្នកចូលរួម ៤ ៧៨០នាក់ សម្រេចបាន ១០០ភាគរយ
- ការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ រួមមាន នាយកនិងនាយករងវិទ្យាល័យធនធាន ១៦២នាក់ និងមន្ត្រីរដ្ឋបាល ១៥០នាក់ ស្ដីពីស្តង់ដាសាលារៀនគំរូ, បុគ្គលិកអប់រំផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ ២៣៧នាក់ មកពីវិទ្យាល័យបណ្តាញ, បុគ្គលិកអប់រំនៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ២៤នាក់ ស្ដីពីការប្រឹក្សាយោបល់និងការណែនាំដល់វិទ្យាល័យធនធាន, បុគ្គលិកអប់រំនៃនាយកដ្ឋានកិច្ចការប្រឡង ២០នាក់ ស្ដីពីការរៀបចំ និងដំណើរការប្រឡង, បុគ្គលិកអប់រំនៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ១០០នាក់ ស្ដីពីប្រព័ន្ធអធិការកិច្ចតំបន់ថ្មី ។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

## ២. មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពដំណាក់កាលទី៣ (CDPF 3)

- ថវិកាសរុប ៖ ៣៧,៩ លានដុល្លារអាមេរិក រយៈពេលអនុវត្តពីឆ្នាំ២០១៨ ដល់២០២៦
- មូលនិធិនេះ ផ្តោតលើការពង្រឹងសមត្ថភាពមន្ត្រី និងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការរៀបចំផែនការ ការពិនិត្យតាមដាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តគោលនយោបាយ និងគាំទ្រអាទិភាពកំណែទម្រង់ផ្សេងទៀត។

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

- ការវិភាគស្ថានភាពនៃការអប់រំឌីជីថលនៅកម្ពុជា ការពិនិត្យឡើងវិញលើឧត្តមានុវត្តន៍ជាសកល និងក្នុងតំបន់ដើម្បីជាមូលដ្ឋានក្នុងការអភិវឌ្ឍគោលនយោបាយអប់រំឌីជីថល
- ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ស្របនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ គោលដៅអភិវឌ្ឍដោយចីរភាព អាទិភាពកំណែទម្រង់
- ការបណ្តុះបណ្តាលមន្ត្រីអប់រំ យុវជន និងកីឡាស្រុកចំនួន ១២០ ស្តីពីរបៀបពិនិត្យតាមដានមូលនិធិដំណើរការសាលារៀន (SOF)។

# បញ្ហានានានៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

២. មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពជំណាក់កាលទី៣ (CDPF 3)

វឌ្ឍនភាពសំខាន់ៗ រួមមាន ៖

- ការគាំទ្រដល់ការអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូបង្រៀន ដែលគ្របដណ្តប់លើកម្មវិធីសិក្សា និងស្តង់ដាបណ្តុះបណ្តាលគ្រូបង្រៀនទាំងអស់ (កុមារតូច បឋមសិក្សានិងមធ្យមសិក្សា)។
- ការបន្តគាំទ្រការអប់រំនៅក្នុងសាលារៀនពហុភាសារួមទាំងការអភិវឌ្ឍសម្ភារៈអំណាន សម្រាប់សិស្សថ្នាក់ទី២ និងទី៣ ទាំងប្រាំភាសា និងការបណ្តុះបណ្តាលគ្រូបង្រៀនតាមវិធីសាស្ត្រពហុភាសាថ្មីនៅខេត្តរតនគិរី រួមមាន ការបណ្តុះបណ្តាលគ្រូ និងនាយក ២៧១នាក់ លើការអប់រំពហុភាសា ការបណ្តុះបណ្តាលគ្រូបង្រៀន ២៨នាក់ មកពីវិទ្យាល័យអប់រំពិសេសអំពីកម្មវិធីអប់រំពហុភាសា វិន័យ និងអាកប្បកិរិយាវិជ្ជមាន
- ការគាំទ្រការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានចាប់ផ្តើមនៅដើមឆ្នាំ ២០២៣។ វគ្គសិក្សារួមមានម៉ូឌុលជម្រើសមួយស្តីពីសមភាពយេនឌ័រ និងបរិយាបន្ន។ វគ្គសិក្សាភាពជាអ្នកដឹកនាំ ផ្តល់ឱ្យថ្នាក់ដឹកនាំមន្ទីររាជធានី ខេត្ត ជាពិសេសផ្តោតលើថ្នាក់ដឹកនាំជាស្ត្រី។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

## ៣. គម្រោងកែលម្អការអប់រំនៅឧត្តមសិក្សា (HEIP)

- ថវិកាសរុប ៖ ៩២,៥លានដុល្លារអាមេរិក រយៈពេលអនុវត្តពីឆ្នាំ២០១៨ ដល់ ២០២៤
- គោលបំណងនៃគម្រោង ៖ កែលម្អសមត្ថភាពនៃការរៀននិងការបង្រៀន និងស្រាវជ្រាវដោយផ្ដោតលើស្ទែម កសិកម្ម និងការពង្រឹងប្រព័ន្ធអភិបាលកិច្ចនៃអនុវិស័យឧត្តមសិក្សា

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

- ត្រឹមឆ្នាំ២០២៣នេះ កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្របានបង្កើតថ្មី និងកែលម្អមាន ៧៩។ ប្លង់មេរៀន ១ ៥០៣ ក្នុងចំណោម ១ ៤៣២, ប្រព័ន្ធ៥ ក្នុងចំណោម៦ ត្រូវបានបង្កើតឡើង និងកំពុងអនុវត្ត។ មន្ត្រីអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា ៣០៤នាក់ បាននឹងកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត
- កម្មវិធីភាពជាដៃគូក្នុងស្រុកសម្រាប់ការអប់រំស្ទែម គ្រឹះស្ថានឧត្តមសិក្សាគោលដៅទាំង៥ បានបណ្ដុះបណ្ដាលទាំងទ្រឹស្ដី និងការអនុវត្តលើបំណិនកសិកម្ម និងបច្ចេកវិទ្យា ២១ ដល់គ្រូបង្គោល ៣៩១នាក់ មកពីសាលាមធ្យមសិក្សា ១០២។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

## ៣. គម្រោងកែលម្អការអប់រំនៅឧត្តមសិក្សា (HEIP)

### វឌ្ឍនភាពសំខាន់ៗ រួមមាន ៖

- ការសាងសង់អគារមជ្ឈមណ្ឌលស្រាវជ្រាវ និងបណ្តុះបណ្តាលកសិកម្មរបស់សាកលវិទ្យាល័យជាតិបាត់ដំបងបានសាងសង់រួចរាល់នៅចុងឆ្នាំ២០២៣ និងត្រៀមបំពាក់មូលដ្ឋានសម្ភារៈ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅដើមឆ្នាំ២០២៤, កំពុងសាងសង់អគារសិក្សាអន្តេវាសិកដ្ឋាន ២ និងមជ្ឈមណ្ឌលភ្ញាស់ធុរៈកិច្ចរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- អត្ថបទស្រាវជ្រាវបែបវិទ្យាសាស្ត្រ ៧៧ ត្រូវបានបោះពុម្ពនៅក្នុងទស្សនាវដ្តីស្រាវជ្រាវអន្តរជាតិ និងអត្ថបទ ២០ ទៀតបានបោះពុម្ពនៅក្នុងទស្សនាវដ្តីស្រាវជ្រាវជាតិ
- គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ៤៩ បានចូលរួមអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ដោយបានធ្វើស្វ័យវាយតម្លៃគុណភាពកម្រិតកម្មវិធីបាន ៨៨កម្មវិធី សម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២៣។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

## ៤. គម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP)

- ថវិកាសរុប ៖ ៧០,២៥ លានដុល្លារអាមេរិក រយៈពេលអនុវត្តពីឆ្នាំ២០២២ ដល់ ២០២៦
- គោលបំណងនៃគម្រោង ៖ កែលម្អ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស កែលម្អគុណភាព និងសមធម៌ការអប់រំចំណេះទូទៅ ឱ្យសម្រេចបានស្តង់ដាអប្បបរមានៅតំបន់គោលដៅ។

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

- ការសម្រេចបានស្តង់ដាអប្បបរមា សាលារៀនគោលដៅ ៥២ភាគរយ នៃសាលាមត្តេយ្យសិក្សាគោលដៅ ២១៣, សាលាបឋមសិក្សា ៦២ភាគរយ នៃសាលាបឋមសិក្សាគោលដៅសរុប ១ ០០០ និងសាលាមធ្យមសិក្សាចំណេះទូទៅ ៥៦ភាគរយ នៃសាលាមធ្យមសិក្សាគោលដៅសរុប ៤៣៥
- គ្រូបង្រៀនប្រើប្រាស់វិធីសាស្ត្របង្រៀនមានប្រសិទ្ធភាព សម្រាប់អំណានភាសាខ្មែរ និងគណិតវិទ្យា នៅកម្រិតបឋមសិក្សាថ្នាក់ខ្ពស់ ២ ២៧២នាក់ ស្រី ១ ៤៥០នាក់

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

## ៤. គម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP)

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

- ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្របរិស្ថានសិក្សា ៖ បានជួសជុលអគារសិក្សា និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ៩៦, បានបំពាក់សម្ភារក្នុងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ១៣, កំពុងសាងសង់អគារសិក្សាសាលាមធ្យមសិក្សា ៦៨, កំពុងរចនាប្លង់អគារសិក្សា ២ខ្នង សម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
- សិក្ខាសាលាលើកទី២ ស្តីពីយុទ្ធសាស្ត្រសហគមន៍សាលារៀនដល់អនុវិស័យទាំង៣ មានអ្នកចូលរួម ១ ២៣៥ នាក់ ស្រី ១២៧នាក់
- សាលារៀនគោលដៅ ១០០ភាគរយ នៃគម្រោង បានរៀបចំផែនការគាំទ្រកុមាររៀនយឺត និងមានពិការភាព
- សាលាមធ្យមសិក្សាគោលដៅ ១០០ភាគរយ បានប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន និងរៀន
- ការផ្តល់កុំព្យូទ័រយួរដៃ ម៉ាស៊ីនព្រីនធ័រ និងLCD Projector ទៅដល់សលារៀនគោលដៅ និងថ្នាក់មន្ទីរអ.យ.ក.
- គ្រូបង្រៀន និងថ្នាក់ដឹកនាំសាលារៀនបានចូលរួមវគ្គបណ្តុះបណ្តាលវិក្រឹតការស្តីពីកម្មវិធីបង្កើនគុណវុឌ្ឍិនៅសាលាកលវិទ្យាល័យភូមិន្ទភ្នំពេញ ៦ ៦២៣នាក់ ស្រី ២ ៦៦០នាក់។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

៥. គម្រោងការគ្រប់គ្រងទិន្នន័យអប់រំនៅមធ្យមសិក្សាប្រកបដោយប្រសិទ្ធភាព ដើម្បីជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម កម្ពុជា និងប្រទេសក្នុងតំបន់ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (មេគង្គឡានឆាង)

- ថវិកាសរុប ៖ ៤៥៨ ៥០០ដុល្លារអាមេរិក មានរយៈពេលអនុវត្ត ១៧ខែ (២០២៣-២០២៤)
- គម្រោងនេះផ្ដោតលើ ការកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅមធ្យមសិក្សាចំណេះទូទៅរបស់កម្ពុជាឱ្យឆ្លើយតបទៅនឹងតម្រូវការស្តង់ដារអប់រំក្នុងស្រុក និងតំបន់។

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

- សាលារៀនមធ្យមសិក្សាចំណេះទូទៅ ១០០ បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃការអប់រំមធ្យមសិក្សាចំណេះទូទៅ
- ការបំប៉នសមត្ថភាពមន្ត្រីថ្នាក់ជាតិ រាជធានី ខេត្ត និងមន្ត្រីគម្រោង ស្តីពីការវិភាគស្ថានភាព ការគ្រប់គ្រងទិន្នន័យអនុវិស័យមធ្យមសិក្សា ៤៦៣នាក់ ស្រី ៦៩នាក់ ក្នុងនោះ ថ្នាក់ជាតិ ១៣៧នាក់ ស្រី ៣២នាក់ ថ្នាក់រាជធានីខេត្ត ២១៦នាក់ ស្រី ៣៤នាក់ និងមន្ត្រីគម្រោង ១១០ នាក់ ស្រី ៣នាក់។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

៦. គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ (STEP UP)

– ថវិកាសរុប ៖ ៧៨,២៤ លានដុល្លារអាមេរិក រយៈពេលអនុវត្តពីឆ្នាំ ២០២៣ ដល់២០២៨។
– គម្រោងនេះផ្តោតលើ ១).ការបង្កើនលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព ២).ការពង្រឹងការបង្រៀន និងរៀនវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និង៣).ការពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាពគ្រប់គ្រងអប់រំ។

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

– ការវាយតម្លៃលើការជួសជុលវិទ្យាល័យធនធាន ៨ ដែលត្រៀមខ្លួនក្លាយសាលាជំនាន់ថ្មី
– ការវាយតម្លៃជួសជុលថ្នាក់រៀន ២បន្ទប់ឱ្យទៅជាបន្ទប់ថ្នាក់រៀនវិទ្យាសាស្ត្រ ២ នៅតាមវិទ្យាល័យបណ្តាញ ១៧ វិទ្យាល័យចំណោះទូទៅ និងបច្ចេកទេស ៤ និងសាលាមធ្យមសិក្សាទុតិយភូមិ ១០៣ និងជួសជុលបន្ទប់រៀន ១ បន្ទប់ទៅជាបណ្ណាល័យនៅតាមសាលាមធ្យមសិក្សាបណ្តាញ ១៧ និងសាលាមធ្យមសិក្សាទុតិយភូមិ ១០៣

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

៦. គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ (STEP UP)

វឌ្ឍនភាពសំខាន់ៗ រួមមាន ៖

- ការប្រមូលទិន្នន័យអំពីឧបករណ៍វិទ្យាសាស្ត្រ និងឧបករណ៍សុវត្ថិភាពថ្នាក់រៀន និងវិទ្យាសាស្ត្រ
- ការបញ្ចប់កម្រងការកិច្ច និងឯកសារពាក់ព័ន្ធនៃកញ្ចប់លទ្ធកម្មលើការជ្រើសរើស ក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សាសមិទ្ធិផល និងអ្នកឯកទេសផ្នែកវិទ្យាសាស្ត្រ សម្រាប់ដំណើរការមជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកម្ពុជា (CSTC)
- ការប្រមូលធាតុចូលជាមួយអង្គភាពពាក់ព័ន្ធសម្រាប់បង្កើតកម្រងតួនាទី និងភារកិច្ច (ToR) នៃការរចនា និងអគារ CSTC
- ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅសាលារៀន។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

**៧. គម្រោងបង្កើតប្រព័ន្ធបណ្តុះបណ្តាលធុរៈកិច្ចរវាងសាកលវិទ្យាល័យ និងឧស្សាហកម្មនៅកម្ពុជា**

- គាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)
- ថវិកាសរុប ៖ ៧,៩១លានដុល្លារអាមេរិក រយៈពេលអនុវត្តពីឆ្នាំ២០១៩ ដល់ ២០២៤
- គោលបំណងនៃគម្រោង ៖ កសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យា និងពង្រឹងសមត្ថភាពប្រតិបត្តិការសម្រាប់ការធ្វើឱ្យមានប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី។

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

- ការដំឡើងគ្រឿងសម្ភារ និងបរិក្ខារសម្រាប់មជ្ឈមណ្ឌលជាតិបណ្តុះធុរកិច្ចថ្មីនៃកម្ពុជា (NICC)
- ការងារសាងសង់មជ្ឈមណ្ឌលជាតិបណ្តុះធុរកិច្ចថ្មីនៃកម្ពុជា (NICC)ត្រូវបានបញ្ចប់
- កម្មវិធីបណ្តុះបណ្តាលបុគ្គលិករបស់មជ្ឈមណ្ឌល NICC ក្នុងស្រុកចំនួន ៥ សម្រាប់ការកសាងសមត្ថភាពស្តីពីការណែនាំការចាប់ផ្តើមអាជីវកម្ម និងការសរសេរផែនការសម្រាប់ប្រតិបត្តិការរបស់ NICC
- កម្មវិធីបណ្តុះបណ្តាលនៅសាធារណរដ្ឋកូរ៉េ ១ បានធ្វើឡើងសម្រាប់បុគ្គលិក ១៧នាក់

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

៧. គម្រោងបង្កើតប្រព័ន្ធបណ្តុះបណ្តាលធុរកិច្ចរវាងសាកលវិទ្យាល័យ និងឧស្សាហកម្មនៅកម្ពុជា

វឌ្ឍនភាពសំខាន់ៗ រួមមាន ៖

- ការចូលរួមពិព័រណ៍ចាប់ផ្តើមអាជីវកម្មជាសកលដែលធ្វើឡើងនៅសាធារណៈរដ្ឋកូរ៉េ (COMEUP 2023) បានផ្តល់ទៅឱ្យអ្នកតំណាង ៩នាក់ នៃសហគ្រិន៥ ជាអតីតនិស្សិតនៃកម្មវិធីបណ្តុះធុរកិច្ចថ្មីរបស់ NICC ដើម្បីបង្ហាញអំពីអាជីវកម្មរបស់ពួកគេទៅកាន់ទីផ្សារពិភពលោក និងជាគំរូរបស់អ្នកដទៃ
- Networking Day លើកទី៣ មានអ្នកចូលរួម ៦២នាក់ និងទី៤ មានអ្នកចូលរួម ៧៧នាក់ ដើម្បីផ្តល់ដំណាក់កាលដល់តារាផ្ទើមដើម្បីបង្ហាញពីអាជីវកម្មរបស់ពួកគេទៅដល់វិនិយោគិន និងដៃគូ
- សន្និសីទ Technology Sharing Conference លើកទី៦ មានអ្នកចូលរួម ៧៥៨នាក់ និងទី៧ មានអ្នកចូលរួម ៨០៧នាក់ ដើម្បីណែនាំអំពីបច្ចេកវិទ្យា និងគំនិតអាជីវកម្មថ្មីៗដល់សហគ្រិន និងនិស្សិតសាកលវិទ្យាល័យ
- កម្មវិធីផ្លាស់ប្តូរនិស្សិតកម្ពុជា-សាធារណៈរដ្ឋកូរ៉េ លើកទី៣ និស្សិត ៤០នាក់ នៃប្រទេសទាំងពីរ
- ការប្រកួតការបង្កើតរ៉ូបូតរបស់សិស្សមធ្យមសិក្សាទុតិយភូមិលើកទី២ អ្នកចូលរួម ១០៥នាក់ (វិទ្យាល័យ ៥)។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

## ៨. គម្រោងកសាងសមត្ថភាពបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអប់រំមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា

- ថវិកាសរុប ៖ ៧ លានដុល្លារអាមេរិក រយៈពេលអនុវត្តពីឆ្នាំ២០២១ ដល់ ២០២៦
- គោលបំណងនៃគម្រោង ៖ លើកកម្ពស់គុណភាពការបណ្តុះបណ្តាលគ្រូមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) និងការអប់រំមធ្យមសិក្សាបឋមភូមិ។
- ផ្តោតលើ១)ការកែលម្អបរិយាកាសបង្រៀនសម្រាប់គរុនិស្សិត និងគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ២) ការអភិវឌ្ឍកម្មវិធីសិក្សាមុខវិជ្ជា ICT និងសម្ភារឧបទេស ៣) កម្មវិធីកសាងសមត្ថភាពគ្រូឧទ្ទេស និងគ្រូតាមសាលារៀនគោលដៅ ៤) ការកែលម្អបរិយាកាសសិក្សាសម្រាប់សិស្ស និងគ្រូនៅតាមសាលារៀនគោលដៅ ៥) ការអភិវឌ្ឍកម្មវិធីសិក្សាមុខវិជ្ជា ICT និងសៀវភៅសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ និង ៦) ការពង្រឹងកម្មវិធីគាំទ្រការអប់រំមុខវិជ្ជា ICT។

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

- ការបណ្តុះបណ្តាលអ្នកបង្កើតគោលនយោបាយថ្នាក់ដឹកនាំសាលាឈានមុខ ICT ២០នាក់ និងមន្ត្រី ៤នាក់ នៅសាធារណៈរដ្ឋកូរ៉េ

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

៨. គម្រោងកសាងសមត្ថភាពបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអប់រំមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា

វឌ្ឍនភាពសំខាន់ៗ រួមមាន ៖

- កម្មវិធីសិក្សា ICT នៃអនុវិទ្យាល័យត្រូវបានកែលម្អក្នុងឆ្នាំ ២០២៣ និងចងក្រងសៀវភៅសិក្សា ICT សម្រាប់ថ្នាក់ទី ៧, ៨, និង ៩ ក្នុងឆ្នាំ ២០២៣
- ការរៀបចំកម្មវិធីសិក្សា និងចងក្រងសៀវភៅសិក្សា ICT របស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគក្នុងឆ្នាំ២០២២
- ការអនុម័តសៀវភៅសិក្សាមុខវិជ្ជា ICT ៩ចំណងជើង ជាភាសាខ្មែរ និងអង់គ្លេស សម្រាប់ការបណ្តុះបណ្តាលគរុសិស្ស គរុនិស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
- ការលើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេស និងបុគ្គលិកអប់រំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកការអប់រំបច្ចេកវិទ្យាព័ត៌មាន ១៥នាក់ ស្រី ១នាក់ នៅសាធារណរដ្ឋកូរ៉េ
- ការដាក់ឱ្យប្រើប្រាស់បន្ទប់កុំព្យូទ័រ ៤៨ នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ៤ និងសាលាសហការ២០
- គ្រូឧទ្ទេស ៣០នាក់ បានចូលរួមបណ្តុះបណ្តាលក្នុងស្រុកចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី១៤ ខែកក្កដា និងចាប់ពីថ្ងៃទី២៥ ខែកក្កដា ដល់ថ្ងៃទី៥ ខែសីហា ឆ្នាំ ២០២៣។

# វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

៩. គម្រោងសម្រាប់ការបង្កើតវិស្វកម្មបរិស្ថាននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីលើកកម្ពស់ធនធានមនុស្សកម្រិតឧត្តមសិក្សានៅប្រទេសកម្ពុជា

– ថវិកាសរុប ៖ ៦,៩ លានដុល្លារអាមេរិក រយៈពេលអនុវត្តពីឆ្នាំ២០២១ ដល់ ២០២៦

– គោលបំណងនៃគម្រោង ៖ បង្កើតប្រព័ន្ធអប់រំកម្រិតឧត្តមសិក្សាក្នុងជំនាញវិស្វកម្មបរិស្ថាននៅប្រទេសកម្ពុជា ដោយការបង្កើត និងដំណើរការដេប៉ាតឺម៉ង់វិស្វកម្មបរិស្ថាននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**វឌ្ឍនភាពសំខាន់ៗ រួមមាន ៖**

– ការបង្កើតដេប៉ាតឺម៉ង់វិស្វកម្មបរិស្ថាននៅខែធ្នូឆ្នាំ២០២២ គម្រោងបានជ្រើសរើសបេក្ខភាពថ្នាក់អនុបណ្ឌិត ៤នាក់ និងថ្នាក់បណ្ឌិត ៣នាក់ ក្នុងឆ្នាំ២០២៣

– ការបណ្តុះបណ្តាលកសាងសមត្ថភាព សិក្ខាកាម ៤៩ នាក់

– និស្សិត ៤នាក់ ចូលរៀនថ្នាក់បរិញ្ញាបត្រនៃដេប៉ាតឺម៉ង់វិស្វកម្មបរិស្ថាននៅចុងឆ្នាំ២០២២ និង១៤នាក់ ចូលរៀននៅខែមករា ឆ្នាំ២០២៤

– គម្រោងបានទទួលការយល់ព្រមកែលម្អអគារសម្តែងសិល្បៈ ចាប់ផ្តើមជួសជុលនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣។

# ឆ្លើយតបកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ប្រមូលព័ត៌មានសម្រាប់ជាមូលដ្ឋានធ្វើការសិក្សាលើគោលការណ៍ និងកំណត់ជម្រើសជាក់លាក់មួយចំនួន សម្រាប់ដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការប្រើប្រាស់កញ្ចប់ថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក នៅខេត្តបាត់ដំបង ក្រចេះ កំពត និងរាជធានីភ្នំពេញ
- ផែនការសកម្មភាពជាអាទិភាពឆ្នាំ២០២៣ លើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ
- កសាង និងដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំបច្ចេកទេស ស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា
- ពង្រឹងការអនុវត្តមុខងារអប់រំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅរាជធានីភ្នំពេញ ខេត្តស្ទឹងត្រែង កំពត ព្រៃវែង សៀមរាប និងបាត់ដំបង មានអ្នកចូលរួម ១ ១៦៣នាក់ ស្រី ២៤៥នាក់
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលដល់បុគ្គលិកអប់រំក្រុង ស្រុក ខណ្ឌលើសៀវភៅណែនាំបច្ចេកទេសស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរ មានអ្នកចូលរួម ១៥៩នាក់ ស្រី ៣៥ នាក់ នៅខេត្តកំពង់ចាម។

# ឆ្លើយតបនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ

- បុគ្គលិកអប់រំគ្រប់កម្រិតសរុប ១២៤ ៩១៧នាក់ ស្រី ៥៩ ១៦៥នាក់ ត្រូវជា ៤៧,៩១ភាគរយ ក្នុងនោះ ថ្នាក់ជាតិ ៤ ៩៧៨នាក់ ស្រី ១ ៦៥៨នាក់ និងថ្នាក់ក្រោមជាតិ ១១៩ ៩៣៩នាក់ ស្រី ៥៧ ៥០៧នាក់។ គ្រូមត្តេយ្យសិក្សា ៤ ១០៧នាក់ ស្រី ៤ ០០៣នាក់ គ្រូបឋមសិក្សា ៥៣ ១៥៣នាក់ ស្រី ២៩ ១៤៦នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋាន ៤៣ ៣៤៦នាក់ ស្រី ១៨ ៨៣៩នាក់ គ្រូអប់រំកាយនិងកីឡា ២ ៥៧៤នាក់ ស្រី ៥៣០នាក់ គ្រូបង្រៀនកម្រិតឧត្តម ១៩ ៣៣១នាក់ ស្រី ៦ ១៥៩នាក់ គ្រូបង្រៀនកម្រិតឧត្តមបម្រើការងារនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ១ ៦៧១នាក់ ស្រី ៤៣៧នាក់ អធិការបឋម ៤០នាក់ ស្រី ៦នាក់ អធិការមធ្យម និងអធិការអប់រំ ២៩៥នាក់ ស្រី ៤៥នាក់
- ប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ៧០៤នាក់ ស្រី ២៧៨នាក់ ក្នុងនោះថ្នាក់ជាតិ ៤៦១នាក់ ស្រី ១៨៦នាក់ និងថ្នាក់ក្រោមជាតិ ២៤៣នាក់ ស្រី ៩៩នាក់
- ប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ១៥ ៩០២នាក់ ស្រី ៩ ៤៩៦នាក់ ក្នុងនោះគ្រូបង្រៀនជាប់កិច្ចសន្យាចំណេះទូទៅ ១៣ ២៥៦នាក់ ស្រី ១០ ២៩៣នាក់ គ្រូបង្រៀនជាប់កិច្ចសន្យាក្រៅប្រព័ន្ធ ២ ៤៧២នាក់ ស្រី ១ ០០៤ នាក់ និងគ្រូបង្រៀនជាប់កិច្ចសន្យាខ្មែរ-ឥស្លាម ១៧៤នាក់ ស្រី ៥៣នាក់

# ឆ្លើយតបនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ក្នុងឆ្នាំ២០២៣នេះ ក្រសួងអប់រំ យុវជន និងកីឡាបានចំណាយថវិកាកម្មវិធី ដោយបោះផ្សាយអាណត្តិបើកប្រាក់បាន ១០៨,១ភាគរយ ធៀបនឹងច្បាប់ថវិកា ក្នុងនោះ ចំណាយចរន្តនៅរដ្ឋបាលកណ្តាលអនុវត្តបាន ១០៧,៩ភាគរយ ធៀបនឹងច្បាប់ថវិកា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តអនុវត្តបាន ៩៩,៥ភាគរយ ធៀបនឹងច្បាប់ថវិកា និងចំណាយមូលធនអនុវត្តបាន ១១៧,២ភាគរយ ធៀបនឹងច្បាប់ថវិកា។
- ធ្វើបច្ចុប្បន្នកម្ម និងបណ្តុះបណ្តាលប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រោងផែនការថវិកាប្រចាំឆ្នាំ
- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា លើមុខងាររបាយការណ៍ (របាយការណ៍ហិរញ្ញវត្ថុនិងកិច្ចបញ្ជិការ) ដោយបន្សុីវាងរបាយការណ៍អនុវត្តថវិកាជាមួយនឹងរបាយការណ៍សមិទ្ធកម្ម
- អនុវត្តស្វ័យប្រវត្តិកម្មប្រព័ន្ធ FMIS តាមសេចក្តីណែនាំលេខ ០១៤ សហវ.សណន.អល ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០២៣ ស្តីពីការអនុវត្តនីតិវិធីសម្រាប់ចំណាយថវិកាចរន្តដែលមិនមានធានាចំណាយដោយឡែកក្នុងក្របខណ្ឌក្រសួង ៧ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)
- រៀបចំផែនការសកម្មភាពលម្អិតសម្រាប់ការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៤ ឆ្នាំ២០២៤ (MAP4-២០២៤) ដើម្បីចូលរួមគាំទ្រកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

# វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៣ ថ្នាក់ជាតិ

- ក្រសួងបានអនុម័តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣ មានសកម្មភាព ៨៥២ ក្នុងនោះអនុវត្តចប់ ៧៦៣ ស្មើ ៨៩,៦ភាគរយ កំពុងអនុវត្ត ៥៥ ស្មើ ៦,៥ភាគរយ និងមិនបានអនុវត្ត ៣៤ ស្មើ ៤ភាគរយ ។



# បញ្ហាប្រឈម

- អាទិភាពសម្រាប់ការសិក្សាស្រាវជ្រាវមានច្រើន ចំនួនមន្ត្រីនិងថវិកាមិនទាន់ឆ្លើយតប
- លទ្ធផលនៃការអនុវត្តតាមអនុវិស័យ មិនទាន់ឆ្លើយតបទៅនឹងចំណុចដៅទាំងអស់ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ការពិនិត្យតាមដាននិងវាយតម្លៃកម្មវិធី គម្រោងមិនទាន់គ្រប់ជ្រុងជ្រោយ ហើយការរៀបចំរបាយការណ៍សមិទ្ធកម្មនៅមានកម្រិត
- ការរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួនមិនទាន់ឆ្លើយតបនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំ
- ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អមិនទាន់ឆ្លើយតបតាមកម្មវិធីកំណែទម្រង់សាលារៀន
- ខ្វះអ្នកជំនាញក្នុងការធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍឯកសារគាំទ្រសម្រាប់គ្រឹះស្ថានអប់រំគ្រូបង្រៀន។

# សេចក្ដីសន្និដ្ឋាន

– សមិទ្ធផលវិស័យអប់រំ យុវជន និងកីឡា បានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តប្រាជ្ញាស្មារតី ប្រកបដោយទំនួលខុសត្រូវខ្ពស់ មនសិការស្នេហាជាតិ មាតុភូមិ ស្មារតីពុះពាររាល់បញ្ហាប្រឈមទាំងឡាយ។ ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តដោះស្រាយបញ្ហាសេសសល់ ព្រមទាំងដាក់ចេញនូវវិធានការឆ្លើយតបចាំបាច់នានា ដូចបានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងការដ្ឋានកំណែទម្រង់គន្លឹះនានារបស់រាជរដ្ឋាភិបាល ដើម្បីបន្តអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា ឱ្យកាន់តែរីកចម្រើន ប្រកបដោយភាពធន់ រួមចំណែកសម្រេចចក្ខុវិស័យកម្ពុជានៅឆ្នាំ២០៥០។

# សូមអរគុណ !